សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# សម្បទានដីសង្គមកិច្ច

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

១. **ឈៀវ គីមហាក់**

២. **ដាក សម្ផស្ស**

៣. **តាន់ ស៊ុននី**

៤. **ឈួន តិរម្យ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣

**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

រាជរដ្ឋាភិបាលជាបានយកចិត្តទុកដាក់ ចំពោះប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈមិនថាមាន ឬក្រីក្រនោះទេ គឺទីណាមានផលលំបាក ទីនោះមានការជំរុញ និងការយកចិត្តទុកដាក់គ្រប់រូបភាព។ ប្រទេសមួយក្លាយទៅជាប្រទេសអភិវឌ្ឍន៍ និងមានភាពចំរើនបានវាអាស្រ័យទៅនិងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋមានលក្ខណៈធូរធារអាចរកចំណូលបានខ្ពស់ ហើយគ្មានប្រជាពលរដ្ឋណាមួយក្រីក្រ។ យ៉ាងណាមិញ បញ្ហាចោទនៅតែកើតមានឡើងចំពោះប្រជាពលរដ្ឋ ក៏ដូចជាចំពោះរាជរដ្ឋាភិបាលកម្ពុជា ទាំងមូលដែលថាប្រទេសកម្ពុជាទើបតែក្រោកឈរពីសង្គ្រាម គឺ មានប្រជាពលរដ្ឋភាគច្រើនមានកម្រិតជីវភាពក្រីក្រ។

ទោះបីជាមានប្រជាពលរដ្ឋមានកម្រិតជីវភាពក្រីក្រយ៉ាងនេះក៏ដោយ នៅតែរដ្ឋាភិបាលយកចិត្តទុកដាក់ ក្នុងការប្រយុទ្ធប្រឆាំយ៉ាងខ្លាំងចំពោះផែនការកាត់បន្ថយភាពក្រីក្រ និងឈានទៅលុបបំបាត់ឱ្យទាល់តែអស់។ ឃើញថាមានសកម្មភាពគ្រប់បែបយ៉ាងរបស់ រដ្ឋាភិបាល រួមមានជាអាទិ៍៖ ផែនការសម្បទានដីសង្គមកិច្ច សម្រាប់ប្រជាពលរដ្ឋដែលក្រីក្រ គ្មានទីលំនៅ និងគ្មានដីសម្រាប់ធ្វើស្រែ ចម្ការ ចិញ្ចឹមជីវិត ក៏ដូចជាជូនចំពោះកងទ័ព និងកម្លាំងប្រដាប់អាវុធ ឱ្យមានទីលំនៅថ្មីពិតប្រាកដ។ ការធ្វើសម្បទានដីសង្គមកិច្ច គឺជាប្រធាននៃការសិក្សាស្រាវរបស់ក្រុមខ្ញុំបាទ ដូច្នេះតាម រយៈកិច្ចការនេះ និងបង្ហាញលក្ខណៈបទដ្ឋានគិតយុត្ត ក៏ដូចជាភាពជាក់ស្តែងដែលមានស្រាប។

អាស្រ័យហេតុនេះ តាមរយៈកិច្ចការស្រាវជ្រាវនេះសង្ឃឹមថា នឹងអាចជួយសម្រួលដល់ការសិក្សារបស់មិត្តអ្នកអាន ក៏ដូចជាទទួលបានចំណេះដឹងយ៉ាងច្រើន ក្នុងបញ្ហាប្រឈមនានាលើការអនុវត្តជាក់ស្តែង ចំពោះសកម្មភាពផ្តល់សម្បទានដីសង្គមកិច្ចដល់ប្រជាពលរដ្ឋក្រីក្រ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីធ្វើការអភិវឌ្ឍប្រទេសជាតិ និងសេដ្ឋកិច្ចជាតិ។ តាមពិតរយៈពេលនៃការសិក្សាស្រាវជ្រាវមានកម្រិត មិនមានលក្ខណៈផ្ទាល់នោះទេ និងការយល់ដឹងលើប្រធានបទនេះនៅមានខ្វះខាតច្រើនមិនស៊ីជ្រៅទាំងអស់ទេប្រហែលជា អត្ថន័យ និងអត្ថរសមិនបានឡូសិកប៉ុន្មានឡើយ។ ដូច្នេះសូមមេត្តា លោកសាស្ត្រាចារ្យ មិត្តស្តាប់ និងមិត្តអ្នកអានអព្យាស្រ័យដោយក្តីអនុគ្រោះ។

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈៀវ គីមហាក់, ដាក សម្ផស្ស, ធួន តិរម្យ, តាន់ ស៊ុននី** ជានិស្សិត ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ** ជំនាញ **នីតិឯកជន** ជំនាន់ទី១០.២B១ នៃសកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបកូន និងដោយសារព្រះគុណដ៏ថ្លៃថ្លារបស់អ្នកមានគុណទាំងពីរនេះហើយទើបយើងខ្ញុំមានជីវិត ចម្រើនវ័យវឌ្ឍនាការ និងបានចូលសិក្សាតាំងពីថ្នាក់បឋម រហូតដល់ឧត្តមសិក្សា។

ជាមួយគ្នានេះ ក៏សូមថ្លែងអំណរគុណចំពោះ **លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ** ទាំងអស់ដែលបានលះបង់នូវកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងផ្តល់ចំពោះវិជ្ជាដល់ខ្ញុំទាំងអស់គ្នាតាំងពីវ័យកុមាររហូតដល់សព្វថ្ងៃនេះ។ ដោយសារគុណូបការៈរបស់អ្នកទាំងអស់ ដែលបានធ្វើឱ្យយើងខ្ញុំទាំងអស់គ្នាមានចំណេះដឹងអាចសិក្សាស្រាវជ្រាវ ស្វែងយល់អំពីបញ្ហានានាក្នុងសង្គមដើម្បីជាស្ពានទៅអនាគត។

ពិតប្រាកដណាស់ ពិសេសបំផុតសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យណែនាំ **បណ្ឌិត ហាប់ ផល្លី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីជួយណែនាំ ក៏ដូចជាផ្តល់ដំបូន្មាន និងកែសម្រួលកិច្ចការស្រាវជ្រាវនេះ។

សរុបចុងក្រោយ សូមគោរពជូនពរចំពោះលោក អ្នកមានគុណទាំងអស់ សូមបានជួបប្រទះតែនឹងពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀតឃ្លាតឡើយ។

# មាតិកា


សេចក្ដីផ្ដើម ........ 1

ជំពូកទី១ សញ្ញាណ សម្បទានដីសង្គមកិច្ច ........ 2

១.១. អ្វីជាសម្បទានដីសង្គមកិច្ច? ........ 3

១.២. ដីជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច ........ 3

ជំពូកទី២ កម្មវិធីសម្បទានដីសង្គមកិច្ច ........ 4

២.១. កម្មវិធីសម្បទានដីសង្គមកិច្ច ថ្នាក់មូលដ្ឋាន ........ 4

២.២. កម្មវិធីសម្បទានដីសង្គមកិច្ច ថ្នាក់ជាតិ ........ 6

២.៣. ទិដ្ឋភាពជាក់ស្ដែង ........ 7

ជំពូកទី៣ បញ្ហាប្រឈម ........ 7

៣.១. ទិដ្ឋភាពគតិយុត្តនៃការបែងចែកសម្បទានដីសង្គមកិច្ច ........ 8

៣.២. ការអនុវត្តជាក់ស្ដែងនៃការបែងចែកសម្បទានដីសង្គមកិច្ច ........ 9

សេចក្ដីសន្និដ្ឋាន ........ 12

អនុសាសន៍ ........ 13

គន្ថនិទ្ទេស ........ 14

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មាន សិទ្ធិទទួលការធានារ៉ាប់រងសង្គមកិច្ច និង អត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។ សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបាន គោរព។ ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិ ជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[1]

សម្បទានដីសង្គមកិច្ច ជាកម្មវិធីមួយដែលមានលក្ខណៈក្មេងខ្ចី នៅឡើយសម្រាប់កម្ពុជា ដែលកើតចេញនៅថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០០៣ រដ្ឋាភិបាលបានប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ ដើម្បីពិភាក្សាលើសេចក្តីព្រាង គោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ច និងសេចក្តីព្រាងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។

គោលបំណងនៃសម្បទានដីសង្គមកិច្ច គឺជាការបែងចែកទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយសមធម៌ដល់ពលរដ្ឋក្រីក្រ ជាអាទិ ៖ គ្រួសារក្រីក្រដែលគ្មានផ្ទះសំបែងសម្រាប់សង់លំនៅឋាន គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដល់គ្រួសារដែលត្រូវផ្លាស់ប្តូរលំនៅដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ គ្រួសារមាតុភូមិនិវត្ត យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ។[2] គោលបំណងនៃសម្បទានដីសង្គមកិច្ច គឺចូលរួមធ្វើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ៖ ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច សម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូត៍ដល់កម្មករចម្ការធំៗសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងអភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប។[3]

ការអនុវត្តន៍ គោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចជូនពលរដ្ឋក្រីក្រ និងពលរដ្ឋក្នុងមុខសញ្ញាទទួលបានដី ដើម្បីធ្វើការអភិវឌ្ឍដី តាមកំណត់ដោយកិច្ចសន្យាផ្តល់សម្បទានដីសង្គមកិច្ច និងមានកំណត់ដោយអនុក្រឹត្យ ក្នុងការកាត់បន្ថយភាពក្រីក្រ។ តាមរយៈប្រធានបទខាងលើក្រុមយើងខ្ញុំ បានកំណត់ចេញនូវ សញ្ញាណ(I) ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច(II) និងបញ្ហាប្រឈម។

សម្បទានដីជាសិទ្ធិស្របច្បាប់ ដែលបានចែងក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលឬក្រុមមនុស្សដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់។[4] សម្បទានដីត្រូវឡើងក្នុងរូបឆ្លើយតបទៅនឹងប្រយោជន៍សង្គម ឬឆ្លើយតបទៅនឹងផលប្រយោជន៍សេដ្ឋកិច្ចជាតិ។ សម្បទានដីឆ្លើយតបទៅនឹងផលប្រយោជន៍សង្គមជាតិ អនុញ្ញាតឱ្យ អ្នកទទួលផលប្រយោជន៍ពីសម្បទានធ្វើការរៀបចំដីនោះដើម្បីសាងសង់លំនៅឋាន និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ដែលរដ្ឋបានផ្តល់ជូនតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីធានាការចិញ្ចឹមជីវិត។[5]

ប្រជាពលរដ្ឋក្រីក្រ ជាជនដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់ទាំងឡាយ មិនថាការរស់នៅប្រចាំថ្ងៃ នឹងការធ្វើការអភិវឌ្ឍន៍ឱ្យមានដំណើរការទៅមុខ ដោយមិនបានគិតគូរហើយយកចិត្តទុកដាក់ជាចាំបាច់ពីរាជរដ្ឋាភិបាល មកលើពួកគេ ជាកត្តាអវិជ្ជមានមិនទទួលយកបានឡើយ។ ប្រជាជនក្រីក្រ ជួបផលលំបាក់រដ្ឋមិនអើរពើពួកគេនឹងស្លាប់ ការចាប់ផ្តើមអនុវត្តគោលនយោបាយសម្បទានដីសង្គមកិច្ច ដោយផ្តល់ដីសាធារណៈរដ្ឋមកឱ្យពលរដ្ឋក្រីក្រគឺជាយន្តកាលដ៏ល្អបំផុត និងមានការទទួលស្គាល់ដោយពលរដ្ឋក្រីក្រ មានភាពខ្វះខាត ហើយពួកគាត់ក៏បានខិតខំអនុវត្តតាមការណែនាំកំណត់ដោយកិច្ចសន្យាសម្បទានដីសង្គមកិច្ចអស់ពីលទ្ធភាព។

ជាគោលការណ៍សម្បទានដីត្រូវបានកំណត់ចេញជាពីរប្រភេទ ៖ សម្បទានដីសង្គមកិច្ច(១.១) និងសម្បទានដីសេដ្ឋកិច្ច។ កម្មវិធីសម្បទានដីទាំងពីរូបភាពពិតជាបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនចំពោះអ្នកប្រើប្រាស់ដី និងរដ្ឋ។ ដោយឡែកប្រធានបទដែលត្រូវសិក្សាស្រាវជ្រាវនេះគឺទាក់ទងទៅ និងសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាដែលកំពុងអនុវត្តជាប្រចាំឆ្នាំម្តងក្នុងការជំរុញឱ្យមានការអភិវឌ្ឍលើគ្រប់វិស័យ និងនាំឱ្យប្រទេសកំណើនសេដ្ឋកិច្ចខ្ពស់ កាត់បន្ថយភាពក្រីក្រ នឹងពលរដ្ឋគ្រប់ៗរូបត្រូវតែមានកំរិតជីវភាពធូរធារទៅបើធៀបនិងបណ្តាលប្រទេសដ៏ទៃទៀតនៅក្នុងតំបន់ និងក្រៅតំបន់។

---

[4] ច្បាប់ ភូមិបាល ឆ្នាំ២០០១,មាត្រា ៤៨(ពីពេលនេះហៅថា ច្បាប់ភូមិបាល២០០១)។
[5] ច្បាប់ ភូមិបាល២០០១,មាត្រា ៤៩។

## ១.១. អ្វីជាសម្បទានដីសង្គមកិច្ច?

យោងតាម អនុក្រឹត្យលេខ ១៩ អនក្របក ស្តីពីសម្បទានដីសង្គមកិច្ច ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ ២០០៣ បានកំណត់ថា សម្បទានដីសង្គមកិច្ច ៖ ជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមរូបភាពជាដីសម្បទានសង្គមកិច្ចសម្រាប់គោលបំណងសង្គមកិច្ច ទៅដល់ជនក្រីក្រដែលមានភាពខ្វះខាតដីសម្រាប់សាងសង់លំនៅដ្ឋាន និង ធ្វើកសិកម្ម សំដៅទៅលើសកម្មភាពដាំដំណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដើម្បីបំពេញតំរូវការក្នុងមូលដ្ឋាន។[6]

រាជរដ្ឋាភិបាល មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពលរដ្ឋ ដែលរងគ្រោះ និងដែលបានជួបនូវផលលំបាកគ្រប់បែបយ៉ាង ទាំងការការពារ និងការផ្តល់ឱ្យ។ ក្នុងនោះដែរ រដ្ឋក៏បានសម្រេចចេញនូវ អនុក្រឹត្យលេខ ១៩ អនក្រ/បក ស្តីពីសម្បទានដីសង្គមកិច្ច មួយដើម្បីជាភាពងាយស្រួលក្នុងការកំណត់ធ្វើអត្តសញ្ញាណកម្មដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដែលមានលក្ខណៈចាំបាច់ក្នុងការផ្តល់ដីនៅទំនេររបស់រដ្ឋមាន ទៅឱ្យពលរដ្ឋក្រីក្រក្នុងមុខសញ្ញាដែលត្រូវទទួលបានដីសង់លំនៅឋាន និងធ្វើកសិកម្មតាមការកំណត់ដោយអនុក្រឹត្យនេះ។

គ្រួសារក្រីក្រគ្មានដីប្រើប្រាស់មានច្រើន តំរូវការក៏មានច្រើន ភាពស្ទាក់ស្ទើរបស់រដ្ឋក្នុងការអនុវត្តកម្មវិធីសម្បទានដីឱ្យមានលក្ខណៈមួយភាគរយ មានន័យគ្រួសារដែលមានកម្រិតជីវភាពក្រីក្រ គ្មានដីសងលំនៅដ្ឋាន មានប្រភេទមុខរបបដូចបានកំណត់ដោយច្បាប់ ដែលត្រូវមានសិទ្ធិទទួលបានដីពីរដ្ឋពិតប្រាកដ អាចយកទៅជាប្រយោជន៍តាមគោលដៅសម្បទានដីសង្គមកិច្ច។

## ១.២. ដីជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងទ្រព្យសម្បត្តិរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិមានកំណត់ដោយច្បាប់ តាមរូបភាពជាសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច ។ ទ្រព្យទាំងនោះអាចផ្តល់ឱ្យអ្នកទទួលតាមរយៈភតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យា ដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។ ដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច។[7]

---

[6] អនុក្រឹត្យ *ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២,,មាត្រា២។

[7] ច្បាប់ ភូមិបាល២០០១,មាត្រា ១៧។

យន្តការសមាហរណ៍កម្មដីធ្លីរដ្ឋ ក្នុងលក្ខណៈផ្តល់ជាដីសម្បទានក្នុងរូបភាពជាលក្ខណៈ សម្បទានដីសង្គមកិច្ច ឬសេដ្ឋកិច្ច គឺជាផែនការណ៍អភិវឌ្ឍន៍ដ៏ប្រកបដោយចក្ខុវិស័យ ដើម្បីធ្វើយ៉ាងណាឱ្យដីទំនេរជាច្រើនមានការបង្កបង្កើនផល ធ្វើជាលំនៅដ្ឋានសមរម្យ និងមានការរីកចំរើន និងជាស្ពានឆ្ពោះ ទៅដល់ការអនុវត្តគោលនយោបាយកាត់បន្ថយកម្រិតជីវភាពក្រីក្ររបស់ប្រជាពលរដ្ឋទាំងមូល។

ដោយសង្កេតឃើញថា សកម្មភាពនៃសម្បទានដីទាំងពីរប្រភេទរបស់រាជរដ្ឋាភិបាលបានធ្វើ និងកំពុងធ្វើយ៉ាងសកម្ម និងយកចិត្តទុកដាក់បំផុតក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ អភិវឌ្ឍន៍សង្គមជាតិ ឱ្យឈានដល់ការអភិវឌ្ឍន៍រីកចំរើនគ្រប់ជ្រុងជ្រោយ។

## ជំពូកទី២ កម្មវិធីសម្បទានដីសង្គមកិច្ច

គោលបំណងសំខាន់ក្នុងការធ្វើសម្បទានដីសង្គមកិច្ច គឺធ្វើយ៉ាងណាដើម្បីទាញប្រយោជន៍សង្គមជាតិ និងលើកកំពស់កំរិតជីវភាព របស់ប្រជាពលរដ្ឋក្រីក្រមួយចំនួនដែលជួបការលំបាក និងរស់នៅក្នុងស្ថានភាពក្រីក្រគ្មានដី។ ចំពោះការធ្វើសម្បទាននេះត្រូវធ្វើតាមការផ្តួចផ្តើម ពីថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ ជាពិសេសដោយអមជាមួយយន្តការមួយ ច្បាស់លាស់ដែលជាយន្តការ សម្បទានដីសង្គមកិច្ច ដែលមានបេសកម្មផ្តួចផ្តើម រៀបចំកម្មវិធីសម្បទាន ចូលរួមក្នុងការសំរេចលើ ផែនការសម្បទាន និងការអនុវត្តន៍ផែនការ សម្បទានដីសង្គមកិច្ច ដើម្បីធ្វើការបែងចែកដីឲ្យប្រជាពលរដ្ឋដោយមានតម្លាភាព និងប្រសិទ្ធិភាព។

### ២.១. កម្មវិធីសម្បទានដីសង្គមកិច្ច ថ្នាក់មូលដ្ឋាន

កម្មវិធីសម្បទានដី សង្គមកិច្ចថ្នាក់មូលដ្ឋាន ត្រូវបានប្រគល់សមត្ថកិច្ចឱ្យអាជ្ញាធរដែនដីជាអ្នកផ្តួចផ្តើមក្នុងការស្នើសុំសម្បទាន មានជាអាទិ៍ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ ប្រជាពលរដ្ឋផ្ទាល់ដែលមានចំនួនច្រើននាក់ ឬម្នាក់ ឬតាមរយៈអង្គការ ដែលធ្វើការជាមួយប្រជាពលរដ្ឋ ដែលតំណាងឱ្យប្រជាពលរដ្ឋ មានសិទ្ធិរៀបចំផែនការសម្បទានដីសង្គមកិច្ច។[8]

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវធ្វើប្រចាំឆ្នាំ ដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-

[8] ដដែល,មាត្រា៩,១០,១១,១២,១៣,១៤។

សង្កាត់។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវកំណត់ឱ្យបានច្បាស់នូវគោលដៅសង្គមកិច្ច ឬគោលដៅជាច្រើនទៀត។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារ ថ្នាក់ស្រុក ខណ្ឌទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីសុំការសំរេចយល់ព្រម។[9]

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង អាចផ្តល់ការសំរេចយល់ព្រម លើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ប្រសិនបើផែនការសម្បទានដីសង្គមកិច្ចនោះត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹងទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អំពីផែនការនីមួយ ដែលគណៈកម្មការប្រើប្រាស់ និងបែងចែកដី ថ្នាក់ រាជធានី ខេត្ត បានផ្តល់ការសំរេចយល់ព្រម។

គណៈកម្មាធិការសម្បទានដី សង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការណ៍ ឬ សេចក្តីសំរេចយល់ព្រមរបស់គណៈកម្មការជាតិ ប្រើប្រាស់ និង បែងចែកដីថ្នាក់រាជធានី ខេត្ត ត្រូវជូនដំណឹងទៅ គណៈកម្មការប្រើប្រាស់ និង បែងចែកដី ថ្នាក់ជាតិ អាចពិនិត្យ កែសម្រួលផែនការ ឬ លុបចោលសេចក្តីសំរេចយល់ព្រម។

គណៈកម្មការសម្បទានដី សង្គមកិច្ច ថ្នាក់ជាតិ អាចពិនិត្យកែសំរួល ផែនការ ឬ លុបចោលសេចក្តីសំរេច របស់គណៈកម្មការប្រើប្រាស់ និងចែកដីថ្នាក់ ខេត្ត ក្រុង បានក្នុងរយៈពេល ៦០ គិតចាប់ពីថ្ងៃដែលទទួលបាន ផែនការសម្បទានសង្គមកិច្ចនេះ។ ប៉ុន្តែការកែតម្រូវ ឬ លុបចោលនេះ អាចធ្វើទៅបានលុះត្រាតែ ផែនការសម្បទានដីសង្គមកិច្ចនោះមិនសមស្រប និងអាទិភាពនៃការប្រើប្រាស់ដី ថ្នាក់ជាតិ មានកំហុសបច្ចេកទេស។[10]

ប្រសិនបើ គណៈកម្មការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អនុម័តលើផែនការ សម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួល ការសម្រេចរួចហើយ ត្រូវបើកចំហជាសាធារណៈ នៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធទៅគណៈកម្មធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងនៅគណៈកម្មការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ។

---

[9] អនុក្រឹត្យ *ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២ ,មាត្រា៦។
[10] អនុក្រឹត្យ *ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២,មាត្រា៩។

## ២.២. កម្មវិធីសម្បទានដីសង្គមកិច្ច ថ្នាក់ជាតិ

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវបានផ្តួចផ្តើមឡើងដោយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន មិនអាចធ្វើបាន ពិសេសក្នុងស្ថានភាពដែលមានកម្មវិធីអភិវឌ្ឍន៍ដីនៅតំបន់ដាច់ស្រយាល ដែលពុំទាន់មានប្រជាជនមូលដ្ឋានគ្រប់គ្រាន់ដើម្បីអភិវឌ្ឍន៍ដីនោះ។[11]

ការតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើន ដូចជាករណីដំណោះស្រាយសំណង់បណ្តោះអាសន្ននៅតាមទីប្រជុំជន ឬគ្រួសារដែលត្រូវបានផ្លាស់ប្តូរទីកន្លែង។ សម្បទានដីសង្គមកិច្ចអាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម ឬកម្មវិធីអភិវឌ្ឍន៍ថ្មី ឬមានកម្មវិធីអភិវឌ្ឍន៍ស្រាប់ដែលត្រូវសម្របសម្រួលដោយថ្នាក់ជាតិ ដូចជាកម្មវិធីដែលគាំទ្រដោយអ្នកផ្តល់ជំនួយឬអ្នកវិនិយោគ។

ការផ្តួចផ្តើមផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងដែលពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ។ [12] កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយត្រូវអនុវត្តដោយក្រសួង ស្ថាប័ន ឬម្ចាស់សំណើតាមការកំណត់ នៅក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិចែងផ្សេងពីនេះ។

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ-សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិក្នុងអំឡុងម៉ោងធ្វើការ។[13]

---

[11] អនុក្រឹត្យ *ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២,, មាត្រា៧,៨។

### ២.៣. និទ្ទភាពជាក់ស្តែង

ផ្អែកលើស្ថានភាពជាក់ស្តែង ដែលបានកើតមាន និងកំពុងកើតមានក្នុងព្រះរាជាណាចក្រកម្ពុជា ការធ្វើសម្បទានដីសង្គមកិច្ចច្រើនតែអនុវត្តទៅលើការរុះរើលំនៅឋានថ្មី (ការផ្លាស់ប្តូរពីតំបន់ចាស់ទៅកាន់តំបន់ថ្មី) ក្រោមការតាំងទីលំនៅថ្មី រួមមានដូចជាៈ តំបន់ភូមិអណ្តូង និងតំបន់ដំណាក់ត្រយឹង ជាដើម។[14]

ភាពជាក់ស្តែងឃើញថា ការគ្រប់គ្រងបញ្ជីឈ្មោះអ្នករស់នៅក្នុងសំណង់មិនទាន់រៀបរយនៅឡើយដូចជាក្នុងភូមិសំបុកចាប ឬតំបន់សំបុកចាបគឺជាសំណង់អនាធិបត្យយដែលសំបូរប្រជាជនក្រីក្ររស់នៅតិតពីឆ្នាំ១៩៩២ ប្រជាជនដែលរស់នៅភូមិសំបុកចាបមានចំនួន ៣៨៦ គ្រួសារ។ ឆ្លងតាមការជំរឿនបញ្ជីឈ្មោះអ្នករស់នៅក្នុងសំណង់មិនទាន់រៀបរយ គិតត្រឹម ថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០៦ គឺរយៈពេល ១៤ (ដប់ បួន) ឆ្នាំ មានចំនួន ១៣៥២ គ្រួសារ ប៉ុន្តែអ្វីដែលគេស្មានមិនដល់ចំនួនត្រូវបានកើនឡើងពីរដង គិតត្រឹម ថ្ងៃទី ៦ មិថុនា ឆ្នាំ២០០៨ គឺមានចំនួន ៣១៦៣គ្រួសារ វាជាកើននៃប្រជាជនក្រីក្រ ឬអ្នកដែលចូលទៅរស់នៅក្នុងសំណង់មិនទាន់រៀបរយ។

ដោយឡែកតំបន់ដីក្រហម បញ្ជីឈ្មោះគ្រួសារដែលទទួលស្គាល់ដោយអភិបាលខណ្ឌចំការមនចំនួន ២៨៩ គ្រួសារ និងចំនួនគ្រួសារដែលមានឈ្មោះស្ទួនមានចំនួន ៥៨ គ្រួសារដែលបញ្ហាចោទសម្រាប់ការផ្លាស់ប្តូរពួកគេទៅតំបន់ថ្មី តាមរូបភាពកំណត់យកតំបន់ដីក្រហាមមកធ្វើការអភិវឌ្ឍន៍ និងជំនួសមកវិញ ផ្តល់សម្បទានដីសង្គមកិច្ចឱ្យទៅប្រជាជនទាំងនោះរស់នៅក្នុងលំហានថ្មីដែលជាសំណាងមានលក្ខណៈរៀបរយវិញ។

## ជំពូកទី៣ បញ្ហាប្រឈម

បញ្ហាប្រឈម និងភាពកង្វះចន្លោះនៅតែមានក្នុងផែនការសកម្មភាពនៃកម្មវិធីសម្បទានដីសង្គមកិច្ចមួយនេះ ជាហេតុត្រូវតែមានការយកចិត្តទុកដាក់ក្នុងការសម្រេចចិត្តជាមុន ក៍ដូចជាសិក្សាឱ្យបានស៊ីជ្រៅរបស់ស្ថាប័នពាក់ព័ន្ធ នឹងធ្វើការផ្តល់ក្រោយផ្តល់ទៅដល់អ្នកទទួលជាពិសេសគ្រួសារក្រីក្រពិតជាក្រីក្រ និងមានជីវភាពខ្វះខាត់ពិតប្រកដមែន។ ហើយដោយសារតែជីវភាពនៅក្នុងគ្រួសារមានកម្រិតទាប និងស្ថិតតំបន់ដាច់ស្រយាល គឺនាំឱ្យពួកគេបាត់បង់ឪកាសការងារធ្វើការរកបានចំណូលតិចតួច និង ភាពខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធធ្វើឱ្យប្រជាពលរដ្ឋក្រីក្រកាន់តែ

14 ឃាប់ ផល្លី. *នីតិទ្រព្យសម្បត្តិឯកជន*ៈ(ភ្នំពេញ,២០១១),៩៨,(ពីពេលនេះហៅថា ដដែល)។

មានជីវភាពលំបាកយ៉ាងខ្លាំងទាំងក្នុងការចេញទៅធ្វើការ ក៏ដូចជាការធ្វើរបររកស៊ីចិញ្ចឹមជីវិត គ្រួសារ។

ការចាកចេញ ឬបោះបង់ពីលំនៅថ្មីរបស់អ្នកទទួលដីសម្បទានសង្គមកិច្ចព្រោះដោយពួកគេយល់ឃើញថា វាគឺស្ថិតនៅឆ្ងាយពីកន្លែងធ្វើការងារ ពិបាកស្វែងរកការងារ និងធ្វើពួកគេចំណាយកាន់តែច្រើនទៅលើគ្រប់មធ្យោបាយធ្វើដំណើរ។ល។

ការបោះបង់ការសិក្សារបស់កូនចៅអ្នកទទួលដីសម្បទានសង្គមកិច្ច អាចនិងងាយស្រួលក្នុងការទាក់ទាញឱ្យប្រព្រឹត្តអំពើមិនល្អដែលសង្គមស្អប់ខ្ពើម ដែលជាហេតុនាំឱ្យពួកមិនអាចជួយលើកស្ទួយជីវភាពគ្រួសាររបស់ខ្លួនបាននៅពេលអនាគត និងបង្កជាបន្ទុកដល់សង្គមកាន់តែធ្ងន់ធ្ងរ។

ប្រសិនបើគ្មានការយកចិត្តទុកដាក់របស់អាជ្ញាធរមានសមត្ថកិច្ចទេ ដីសម្បទានសង្គមកិច្ច និងត្រូវបានគេធ្វើការលក់ដូររបស់អ្នកទទួលបានសម្បទានដីសង្គមកិច្ច ដោយសារការគ្រប់គ្រងដីធ្លីនៅតំបន់នោះនៅមានការខ្វះចន្លោះច្រើន និងបង្កឱ្យមានជនគ្មានលំនៅឋាននៅតែបន្តគ្មានលំនៅឋានតទៅទៀត។

## ៣.១. និដ្ឋភាពគតិយុត្តនៃការបែងចែកសម្បទានដីសង្គមកិច្ច

លក្ខណៈជាក់ស្តែងការអនុវត្តសកម្មភាពនៃការបែងចែកសម្បទានដីសង្គមកិច្ច នៅមានបញ្ហាប្រឈមភាពចន្លោះប្រហោង ឬភាពខ្វះខាតនូវស្ទើគ្រប់បទដ្ឋានគតិយុត្តជាច្រើន គឺមានន័យថាគ្មានច្បាប់ណាបានកំណត់ពីការបែងចែកដីសម្បទានសង្គមកិច្ចទេរហូតដល់ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១។ គិតមកត្រឹមបច្ចុប្បន្ន យើងមានអនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ចដែលអាចត្រូវបានយកមកអនុវត្តនៅតាមតំបន់ជ្រើសរើសតែប៉ុណ្ណោះ។[15]

កម្មវិធីសម្បទានដីសង្គមកិច្ចអាចអនុវត្តបាន លុះត្រាតែមានកញ្ចប់ថវិកាជាច់ដោយឡែក ដែលស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់យន្តការសម្បទានដីសង្គមកិច្ចបានមកពីថវិការបស់ជាតិ ចំណែកមួយផ្នែកបានមកពីហិរញ្ញប្បទានពីក្នុង និងក្រៅប្រទេស ឬអង្គការផ្តល់

[15] ប្រកាស, *ស្តីពីគោលការណ៍ណែនាំអនុវត្តក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច*,(លេខ៖២០០ ដនស/ប្រក ១៩ វិច្ឆិកា ២០០៣) ប្រការ៣៩។

ជំនួយអន្តរជាតិ។[16] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាអ្នកកំណត់តំបន់ជ្រើសរើស កម្មវិធីសម្បទានដីសង្គមកិច្ច ដើម្បីប្រមូលនូវបទពិសោធន៍ក្នុងការអនុវត្តជំហានដំបូង ធ្វើការ កែលំអ ឈានទៅអនុវត្តទូលំទូលាយទូទាំងព្រះរាជាណាចក្រកម្ពុជា។[17] អាជ្ញាធរឃុំ-សង្កាត់មាន ដំណើរការទៅបានលុះត្រាតែកម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានកំណត់នៅឃុំ- សង្កាត់នោះដែរ។ មិនមានតម្រូវការណាមួយដល់អាជ្ញាធរមូលដ្ឋានក្នុងការត្រៀមលក្ខណៈជាស្រេច ដើម្បីអនុវត្តកម្ម វិធីសម្បទានដីសង្គមកិច្ច។

## ៣.២. ការអនុវត្តជាក់ស្តែងនៃការបែងចែកសម្បទានដីសង្គមកិច្ច

សម្បទានដីសង្គមកិច្ចច្រើនតែអនុវត្តចំពោះការតាំងលំនៅឋានថ្មី ជាការដោះដូររបស់រដ្ឋ ចំពោះប្រជាពលរដ្ឋអ្នក ភូមិសំបុកចាប អ្នកភូមិដីក្រហម និង អ្នកបឹងកក់ ដើម្បីយកតំបន់ទាំងនោះ

- គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិមិនទាន់មានដំណើរការយ៉ាងខ្លាំងទេ។
- សម្បទានដីសង្គមកិច្ចច្រើនតែត្រូវបានផ្តួចផ្តើមដោយស្ថាប័នពាក់ព័ន្ធផ្សេងពីក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់។

យ៉ាងណាមិញតាមភាពជាក់ស្តែងក្នុង ១ឆ្នាំៗ មានកងកម្លាំងប្រដាប់អាវុធដល់ចូលនិវត្តន៍ ហើយកងកម្លាំងប្រដាប់អាវុធខ្លះបាត់បង់សមត្ថភាពការងារ ពិការ ទទួលមរណភាព និងពលិជីវិត ដើម្បីបុព្វហេតុជាតិ ការពារសន្តិភាព បូរណភាពទឹកដី និង អធិបតេយ្យនៃព្រះរាជាណាចក្រ កម្ពុជា។ រាជរដ្ឋាភិបាលបានអនុវត្តន៍ចំពោះកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដោយគោរពដឹង គុណនូវបការៈដ៏ថ្លៃថ្លារបស់ បងប្អូនចំពោះជាតិមាតុភូមិ និងប្រជាជន ជាមួយនឹងការយកចិត្ត ទុកដាក់ដោះស្រាយជីវភាពខាងសម្ភារ ថវិកាជាបន្តបន្ទាប់ រួមមានការបង្កើតផ្តល់នូវរបប ឧបត្ថម្ភ ផ្សេងៗ ព្រមទាំងផ្តល់កិត្តិយស ការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរ ជូនបងប្អូន ស្របតាមស្ថាន ភាពនៃសេដ្ឋកិច្ចជាតិ។

ជាក់ស្តែងរាជរដ្ឋាភិបាលបានអនុវត្តរួចមកហើយ នូវវិធានការ និងគំនិតផ្តួចផ្តើមសម្បទានដី សង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ រួមមានជាអាទិ៍៖

➢ ទី១ ការផ្តល់សម្បទានដីសង្គមកិច្ចនៅក្នុងក្របខណ្ឌ នៃការអនុវត្តគម្រោង វិសាយកងទ័ព។

---

[16] អនុក្រឹត្យ *ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២,មាត្រា៣០។

[17] ប្រកាស,*ស្តីពីគោលការណ៍ណែនាំអនុវត្តក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច*,(លេខ៖២០០ ដនស/ប្រក ១៩ វិច្ឆិកា ២០០៣) ប្រការ៣៩។

- ទី២ ការផ្តល់សម្បទានដីសង្គមកិច្ចសម្រាប់អភិវឌ្ឍយោធិន។
- ទី៣ ការផ្តល់ផ្ទៃដីព្រៃឈើទំហំ ២.៥០៧ ហិកតា ដើម្បីជូនខេត្តសៀមរាប ចំនួន ១.៣១៧ ហិកតា សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច និង ជូនក្រសួងការពារជាតិ ចំនួន ១.១៩០ ហិកតា សម្រាប់បែងចែកជូនគ្រួសារយុទ្ធជន។
- ទី៤ ការរៀបចំបង្កើតភូមិដ្ឋាន សំរាប់គ្រួសារយុទ្ធជនកំពុងបំពេញ ការប្រយុទ្ធ ជនពលីមរណៈ និងពិការ ដែលត្រូវបានដាក់ចេញ និង ជំរុញអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៅតំបន់មួយចំនួន រួមមាន ការផ្តល់សម្បទានដីសម្រាប់យោធិននៅតំបន់តាកែនកោះស្លា ខេត្ត កំពត់ ចំនួន ២៤០គ្រួសារ លើផ្ទៃដី ១២០០ ហិកតា ជូនគ្រួសារយោធិន នៅស្រុកសេនសាន ខេត្ត ស្ទឹងត្រែង ចំនួន ១០០គ្រួសារ លើផ្ទៃដី ១៧៣ ហិកតា ជូនគ្រួសារកងទ័ពនៅស្រុក ជាំក្សាន្ត ខេត្តព្រះវិហារចំនួន ១៩១២គ្រួសារ លើផ្ទៃដី ១៦៤០០ ហិកតា។
- ទី៥ ការកសាងលំនៅដ្ឋាន ជូនអតីតជនមានស្នាដៃឆ្នើម ក្នុងចលនាប្រលងប្រណាំង ល្អ ៣ នៅតាមសហគមន៍ របស់ សមាគមអតីតជនកម្ពុជាក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។
- ទី៦ ការដាក់បញ្ចូនក្នុងគម្រោងវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ២០១០-២០១២ នូវគម្រោងសាងសង់ផ្ទះ និង ភូមិអភិវឌ្ឍន៍អតីតយុទ្ធជន នៅខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ធំ និង កំពង់ចាម។
- ទី៧ ការរៀបចំបង្កើតភូមិដ្ឋានគ្រួសារយោធានៅតំបនបណ្តាលព្រំដែន ភាគខាងជើងដែលថ្មីៗនេះត្រូវបាន និងកំពុងអនុវត្តដោយ គណៈកម្មការអន្តរក្រសួងជាអ្នក សម្រប សម្រួល រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា។ល។

ដោយហេតុនេះហើយដើម្បីសម្រេចគោលដៅ ខាងសង្គមសេដ្ឋកិច្ច ព្រមទាំងការពង្រឹង និងពង្រីកសំណាញ់ សុវត្ថិភាពសង្គម ដូចគូសបញ្ជាក់ខាងលើរាជរដ្ឋាភិបាល ឈរលើគោលការណ៍ សមធម៌ ជាចម្បង ដែលរាជរដ្ឋាភិបាល នឹងរៀបចំជាអាទិភាពនៅក្នុងការរៀបចំគោលនយោបាយ របស់ខ្លួន ដោយកំណត់មុខសញ្ញានៃអ្នកទទួលបាននូវ សម្បទានដីសង្គមកិច្ច នឹងអាទិភាពព្រមទាំង លំដាប់ លំដោយ នៃការផ្តល់ដី សម្បទានសង្គមកិច្ចនេះ ដោយច្បាស់លាស់។

ដោយយល់ឃើញថា រាជរដ្ឋាភិបាលមិនអាច ផ្តល់សម្បទានដីសង្គមកិច្ចដោយឈរលើគោលការ សមភាពជូនដល់គ្រួសារអតីត កងកម្លាំងប្រដាប់អាវុធនេះទេ ដោយសារមូលហេតុ ៖

- ធនធានហិរញ្ញវត្ថុរបស់រដ្ឋមានកម្រិត។
- ការអនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងដី តាមគោលការណ៍ ប្រសិទ្ធិភាព។
- ស្ថានភាពជីវភាពនៃអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសាររបស់គេ នីមួយៗមិនដូចគ្នាទាំងអស់នោះទេ បានន័យថាមានអ្នកមានជីវភាពធូរធា មិនត្រូវការដី និងមានអ្នកក្រីក្រហើយត្រូវការដី។
- សេចក្តីត្រូវការរបស់គ្រួសារនីមួយៗក៏មិនអាចដូចគ្នាដែរ។

# សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងដីរដ្ឋនៅមិនទាន់មានប្រសិទ្ធភាព គ្រួសារក្រីក្រ ជាពិសេសគ្រួសារគ្មានដីនៅមានច្រើនក្នុងសង្គម។ ការបែងចែកដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ចនៅមានភាពយឺតយ៉ាវ និងមិនទាន់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែង។ ការបែងចែកដីតាមរយៈសម្បទានដីសង្គមកិច្ចច្រើនមិនបានអនុវត្តទៅតាមគោលការណ៍ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅឡើយ។

បញ្ហាថវិកាជាឧបសគ្គមួយដ៏ធំដែលនាំឱ្យ មានផលប៉ះពាល់ដល់កម្មវិធីសម្បទានដីសង្គកិច្ចសម្រាប់ប្រជាពលរដ្ឋក្រីក្រ និង ជាបន្ទុករបស់រាជរដ្ឋាភិបាលក្នុងការចាត់ចែងកញ្ចប់ថវិកាក្នុងឆ្នាំនីមួយៗ ឱ្យកាន់តែមាននិរន្តរភាពដើម្បីជំរុញដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចឱ្យមានចរិក ភាព យុត្តិធម៌ និងរហ័សដល់ដៃអ្នកក្រីក្រដែលមានតម្រូវការតាមច្បាប់កំណត់។

ជាការពិតចាប់តាំងពីក្រោយឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចចេញបទដ្ឋានគតិយុត្តជាច្រើន និងបានអនុវត្តន៍គម្រោងកម្មវិធីសម្បទានសង្គមកិច្ចនៅតាមបណ្តាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ ទូទាំងប្រទេសកម្ពុជា ដើម្បីធ្វើកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឱ្យស្របតាមកម្មវិធីគោលនយោបាយជាតិ និងធ្វើឱ្យខានតែបាននូវផែនការអភិវឌ្ឍន៍ជាតិ។ យ៉ាងណាមិញក្រុមដីសម្បទានសង្គមកិច្ចទាំងនោះ មានដីតំបន់ខ្លះបានអនុវត្តន៍យ៉ាងល្អប្រសើ និង មានដីសម្បទានសង្គមកិច្ចតំបនខ្លះទៀតកំពុងអនុវត្តន៍ដោយមានការប៉ះពាល់ដល់ប្រយោជន៍អ្នកដ៏ទៃបង្កើតជាជម្លោះមិនអាចដោះចេញ។

សរុបមកវិញគេសង្កេតឃើញថា ការអនុវត្តន៍កម្មវិធីផ្តល់ដីសម្បទានសង្គមកិច្ច របស់រាជរដ្ឋាភិបាល មិនទាន់មានប្រសិទ្ធិភាព១០០ភាគនៅឡើយនោះទេ។ ភាពខ្វះចន្លោះទាំងអត្ថបទច្បាប់ និងធនធាននៃការអនុវត្តនៅមានកម្រិត ដោយវឡែកវប្បធម៌របស់ខ្មែរគឺក្រុមអ្នកមានទ្រព្យសម្បត្តិ អ្នកមានអំណាច នៅតែបន្តប្រើហឹង្សា គាបសង្កត់ចំពោះប្រជាពលរដ្ឋក្រីក្រដែលទទួលបានដីឥតដាច់ និងមិនខ្លាចរអែងបន្តិចឡើយ។ កត្តាទាំងនេះជាហេតុនាំឲ្យបង្កការរាំងស្ទះដល់ការអនុវត្តន៍មិនអាចសម្រេចបានតាមការគ្រោងទុក។

## អនុសាសន៍

សកម្មភាពរបស់រាជរដ្ឋាភិបាល ទាំងនោះនៅមិនទាន់មានលក្ខណៈមាំមួននៅឡើយទេ ចំពោះកម្មវិធីផ្តល់សម្បទានដីសង្គមកិច្ច ដែលបានអនុម័តសំរេច និង គួរតែបង្កើតយន្តការត្រួតពិនិត្យការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច ដែលទទួលខុសត្រូវក្នុងការបែងចែកដីសម្បទានដី សង្គមកិច្ច ដើម្បីទប់ស្កាត់សកម្មភាពអសកម្មផ្សេងៗដែលអាចកើតមាន។ ជាពិសេសរដ្ឋាភិបាលគួររៀបចំបង្កើតរចនាសម្ព័ន្ធមូលដ្ឋានរួមមាន ផ្លូវ ទឹក ភ្លើង សាលារៀន មន្ទីរពេទ្យ ឬមណ្ឌលសុខភាព និងផ្សារនៅក្នុងតំបន់សម្បទានដីនោះជាមុនសិន។

កម្ពុជា ជាប្រទេសកសិកម្ម ដែលមានប្រជាជនប្រហែលជាង ៧០ % ជាកសិករ ដូច្នេះអាជ្ញាធរមានសមត្ថកិច្ចគួរផ្តល់ការបំប៉នផ្នែកជំនាញវិជ្ជាជីវៈ ជំនាញកសិកម្ម និងជំនាញផ្នែកបច្ចេកវិទ្យាផ្សេងៗឱ្យពួកគេអាចមានជំនាញច្បាស់លាស់។ រដ្ឋគួរបង្កើតការងារឱ្យបានច្រើន និងជំរុញការវិនិយោគនៅជិតតំបន់ដែលមានការតាំងលំនៅឋានថ្មី ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

រដ្ឋត្រូវមានការយកចិត្តទុកដាក់ការផ្តល់ប្រាក់កម្ចីដែលមានការប្រាក់ទាប សម្រាប់ប្រជាពលរដ្ឋក្រីក្រ ដោយត្រួតពិនិត្យប្រវត្តិរបស់គ្រួសារដែលត្រូវខ្ចីប្រាក់ឱ្យមានភាពច្បាស់លាស់ និងគ្រប់គ្រងគោលនយោបាយផ្តល់ប្រាក់កម្ចីឱ្យមានភាពច្បាស់ ហើយជំរុញឱ្យមានទីផ្សារលើផលិតផលដែលផលិតបាន។[18]

គួរជំរុញការបង្កើនធនធានមនុស្ស និងធនធានប្រកបដោយគុណភាពដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឲ្យកាន់តែមានរីកចំរើនជានិរន្តភាព ដោយធ្វើការកសាងអាគារសិក្សា សាលារៀនដែលមានផាសុខភាព និងមានគុណភាពអាចទទួលយកបានសម្រាប់ប្រជាពលរដ្ឋក្រីក្រ។

និយាយជារួម រដ្ឋត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះគ្រួសារក្រីក្រ ដែលទទួលបានដីសម្បទានសង្គមកិច្ច ដែលតម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅចាស់ ទៅរស់នៅតំបន់ថ្មីដែលងាយប្រឈមនិងគ្រោះថ្នាក់ប៉ះពាល់ជាច្រើន។ រដ្ឋត្រូវតែមានវិធានការត្រៀមបង្ការទុកជាមុនដោយឲ្យគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ចំពោះគ្រប់ តម្រូវការចាំបាច់របស់ប្រជាពលរដ្ឋប្រកបដោយយុត្តិ ធម៌ មាននិរន្តរភាព រហ័សទាន់ចិត្ត។

# គន្ថនិទ្ទេស


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- ច្បាប់ ភូមិបាល ឆ្នាំ២០០១។
- អនុក្រឹត្យ,*ស្តីពីសម្បទានដីសង្គមកិច្ច*, លេខ១៩អនក្រ/បក,១៩ មិនា ២០០២។
- ប្រកាស,*ស្តីពីគោលការណ៍ណែនាំអនុវត្តក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច*,(លេខ៖២០០ ដ.នស/ប្រក ១៩ វិច្ឆិកា ២០០៣)។
- ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន* ,៖(ភ្នំពេញ,២០១១)។